# សេចក្តីថ្លែងការណ៍របស់អង្គការមិនមែនរដ្ឋាភិបាលស្តីពីបញ្ហាជាអាទិភាពឆ្ពោះទៅកាន់វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី ៤

សេចក្តីថ្លែងការណ៍ និងចំណាប់អារម្មណ៍របស់អង្គការមិនមែនរដ្ឋាភិបាលនេះ បំពេញបន្ថែមលើឯកសារស្តីពីជំហររបស់អង្គការមិនមែនរដ្ឋាភិបាលចំនួន ២០ វិស័យ ដែលត្រូវបានដាក់ជូនវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី ៣។

ភ្នំពេញ ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១០

*សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត*
*ឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាទីគោរពដ៏ខ្ពង់ខ្ពស់*
*ឯកឧត្តម លោកជំទាវ លោក និងលោកស្រីជាទីគោរព*

សហគមន៍អង្គការមិនមែនរដ្ឋាភិបាល សូមសម្តែងអំណរគុណ និងការវាយតម្លៃខ្ពស់ជូនរាជរដ្ឋាភិបាលកម្ពុជាចំពោះការអនុញ្ញាតឱ្យយើងខ្ញុំចូលរួមនៅក្នុងយន្តការសម្របសម្រួលជំនួយនៅកម្ពុជាពោលគឺ វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (CDCF) កិច្ចប្រជុំប្រចាំត្រីមាសនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ (GDCC) និងតាមរយៈការចូលរួមរបស់តំណាងអង្គការមិនមែនរដ្ឋាភិបាលតាមវិស័យនៅក្នុងក្រុមការងារបច្ចេកទេស(TWGs) ភាគច្រើន។

វិភាគទានរបស់អង្គការមិនមែនរដ្ឋាភិបាលរួមមានឯកសារស្តីពីជំហរចំនួន ២០ វិស័យដែលត្រូវបានដាក់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងត្រូវបានចែកជូនអ្នកចូលរួមទាំងអស់នៅក្នុងកិច្ចប្រជុំនាថ្ងៃនេះ។ អង្គការមិនមែនរដ្ឋាភិបាលជាង ២០០បានចូលរួមយ៉ាងសកម្មក្នុងកិច្ចដំណើរការនេះ ដែលបានចាប់ផ្តើមកាលពីខែ មករា ឆ្នាំនេះ ក្រោយពេលដែលក្រសួងផែនការបានផ្សព្វផ្សាយនូវសេចក្តីព្រាងទីមួយនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣។ នៅក្នុងឯកសារជំហរទាំងនេះ អង្គការមិនមែនរដ្ឋាភិបាលផ្តល់នូវទស្សនៈរបស់ខ្លួនអំពីការអនុវត្តៈ គោលនយោបាយជាតិ កម្មវិធីកំណែទម្រង់ សូចនាករតាមដានរួមឆ្នាំ២០០៨ និង បញ្ហាផ្សេងទៀតដែលគប្បីទទួលបានការយកចិត្តទុកដាក់ពីកិច្ចប្រជុំនេះ។

*សម្តេច ឯកឧត្តម លោកជំទាវ លោក និងលោកស្រីជាទីគោរពៈ*

កិច្ចប្រជុំលើកមុននៃវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាដែលបានប្រព្រឹត្តទៅក្នុងខែធ្នូ ឆ្នាំ២០០៨ បានដំណើរការនៅក្នុងពេលមានវិបត្តិស្បៀងអាហារ។ ការធ្លាក់ចុះសេដ្ឋកិច្ចដែលបានកើតឡើងក្រោយពេលនោះ បាននាំមកនូវការលំបាកបន្ថែមទៀតលើសហគមន៍ក្រីក្រ និងងាយរងគ្រោះនៅកម្ពុជា ដោយសារប្រាក់ចំណូលជាច្រើនរបស់គ្រួសារបានថយចុះ រួមជាមួយនឹងការបាត់បង់ការងារនៅក្នុងវិស័យសំណង់ កាត់ដេរ និងទេសចរណ៍។ នៅក្នុងបរិការណ៍ដ៏លំបាកលំបិននេះ អង្គការមិនមែនរដ្ឋាភិបាលបានបន្តសហការជាមួយស្ថាប័នផ្តល់សេវាផ្នែកសុខភាព និងអប់រំរបស់រាជរដ្ឋាភិបាល ដែលបានរំលេចនូវភាពប្រសើរឡើងគួរឱ្យកត់សម្គាល់ និងជាក់ស្តែងមួយចំនួន។ លទ្ធផលនៃសេវាសុខភាពផ្សេងៗបានប្រសើរឡើងគួរឱ្យកត់សម្គាល់ រួមមានការថយចុះនៃអត្រាមរណៈភាពទារក និងកុមារអាយុក្រោម ៥ ឆ្នាំ, ការធ្លាក់ចុះអត្រាប្រេវ៉ាឡង់មេរោគអេដស៍នៅក្នុងចំណោម

ប្រជាជនទូទៅដែលមានអាយុពី១៥ ដល់ ៤៩ឆ្នាំ និងកំណើននៃការសម្រាលកូនដោយអ្នកផ្តល់សេវាជំនាញ។ ម្យ៉ាងទៀតសាលារៀនកាន់តែច្រើនឡើងត្រូវបានសាងសង់ ហើយកុមារកាន់តែច្រើនឡើងបានចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សា ថ្វីបើនៅមានការបារម្ភជាបន្តអំពីគុណភាពអប់រំ និងអត្រាគង់វង់នៅក្នុងចំណោមក្រុមប្រជាជនជួបការលំបាក។

អង្គការមិនមែនរដ្ឋាភិបាលជឿជាក់ថាជោគជ័យ និងវឌ្ឍនភាពដែលសម្រេចបាននៅក្នុងវិស័យទាំងនេះអាចត្រូវបានធ្វើផងដែរនៅក្នុងវិស័យអភិបាលកិច្ច ដីធ្លី និង ធនធានធម្មជាតិ។ ឯកសារជំហរអង្គការមិនមែនរដ្ឋាភិបាល បង្ហាញយ៉ាងច្បាស់នូវការគាំទ្រទូលំទូលាយចំពោះរបៀបវារៈកំណែទម្រង់ផ្សេង១របស់រាជរដ្ឋាភិបាល និងអាទិភាពទាំងឡាយដែលបានចែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០០៩-២០១៣។ ដោយកសាងលើគ្រឹះដ៏គួរឱ្យសង្ឃឹមទាំងនេះ រាជរដ្ឋាភិបាល សហគមន៍អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ គប្បីធ្វើការរួមគ្នាឆ្ពោះទៅកាន់ការលើកកម្ពស់ទំនុកចិត្តគ្នាកាន់តែខ្លាំងឡើង និងចូលរួមក្នុងលក្ខណៈស្ថាបនានៅក្នុងការពិគ្រោះយោបល់ផ្អែកលើលទ្ធផលឱ្យបានកាន់តែច្រើនឡើងថែមទៀត។

ខណៈដែលឯកសារស្តីពីជំហររបស់អង្គការមិនមែនរដ្ឋាភិបាលតាមវិស័យនីមួយ១ផ្តល់ព័ត៌មានលម្អិតច្រើន និងករណីសិក្សាមួយចំនួន សេចក្តីថ្លែងការណ៍នេះគូសបង្ហាញអាទិភាពអន្តរវិស័យនានា ដែលប្រសិនបើត្រូវបានពិចារណាឱ្យបានល្អ និងស៊ីជំរៅ អាចពង្រឹងកិច្ចសហការរវាង រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ឱ្យបានឈានដល់ជោគជ័យមួយកម្រិតទៀត។ ទីមួយ អង្គការមិនមែនរដ្ឋាភិបាលតាមវិស័យនានាចង់ឃើញការកែលម្អបន្ថែមទៀតនៅក្នុងការប្រតិបត្តិក្របខ័ណ្ឌគតិយុត្តិដែលមានស្រាប់នៅកម្ពុជា ជាពិសេស ច្បាប់ភូមិបាល (រួមទាំងអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច) ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មលើធនធានរ៉ែ និងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។ ក្នុងន័យនេះ អង្គការមិនមែនរដ្ឋាភិបាល សូមស្វាគមន៍ការយកចិត្តទុកដាក់ជាបន្តរបស់រាជរដ្ឋាភិបាលលើកំណែទម្រង់ច្បាប់ និងតុលាការ ដូចដែលបានប្តេជ្ញានៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម។ អង្គការមិនមែនរដ្ឋាភិបាលស្នើសុំឱ្យ ដៃគូអភិវឌ្ឍន៍ផ្តល់ការគាំទ្រពេញលេញចំពោះអាទិភាពនេះ ដោយសារការអនុវត្តក្របខ័ណ្ឌគតិយុត្តិដែលមានស្រាប់មានសក្តានុពលរួមចំណែកជាវិជ្ជមានចំពោះការធ្វើឱ្យប្រសើរឡើងថែមទៀត និងការលើកកម្ពស់ជីវភាពរបស់ប្រជាជនកម្ពុជាក្រីក្រនិងងាយរងគ្រោះរាប់លាននាក់ ជាពិសេស សហគមន៍ជនជាតិដើមភាគតិចដែលមានវត្តមាននៅក្នុងខេត្តចំនួន ១៥ នៃខេត្តទាំងអស់របស់យើង។

អង្គការមិនមែនរដ្ឋាភិបាលទទួលស្គាល់ថាប្រព័ន្ធតុលាការគួរចាំបាច់ត្រូវពង្រឹងបន្ថែមទៀត ដែលជាលទ្ធផលនឹងបង្កើនទំនុកចិត្តរបស់សាធារណជនលើប្រព័ន្ធតុលាការរបស់យើង។ ការពង្រឹងប្រកបដោយប្រសិទ្ធភាព និងភាពសក្តិសិទ្ធិនូវក្របខ័ណ្ឌគតិយុត្តិបច្ចុប្បន្ន អាចជួយដោះស្រាយ និងជៀសវាងវិវាទនានានៅជុំវិញការតាំងលំនៅដ្ឋាននៅទីក្រុង ដីកសិកម្ម រ៉ែ ជលផល និងព្រៃឈើ។ ការពង្រឹងប្រព័ន្ធតុលាការគឺពិតជាអាទិភាពធំបំផុតសម្រាប់រយៈពេលខាងមុខ និងក៏ជាវិស័យមួយដែលអាចទទួលអត្ថប្រយោជន៍ច្រើនពីការជួយគាំទ្ររបស់ដៃគូអភិវឌ្ឍន៍។ ដោយពិនិត្យមើលរបៀបវារៈសម្រាប់កិច្ចប្រជុំថ្ងៃនេះ អង្គការមិនមែនរដ្ឋាភិបាលបានកត់សម្គាល់ឃើញថាកំណែទម្រង់ច្បាប់ និងតុលាការមិនមានវត្តមាននៅក្នុងបញ្ជីនៃកំណែទម្រង់ជាអាទិភាពដើម្បីសម្រេចបានអាទិភាពទាំងឡាយនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (CMDGs)។ ទោះបីជាយ៉ាងណា អង្គការមិនមែនរដ្ឋាភិបាល សូមស្នើឱ្យមានការពិភាក្សាបញ្ហាទាំងនេះខ្លះនៅក្នុងវគ្គទីមួយនៃកិច្ចប្រជុំនេះនៅ

ក្នុងពេលពិភាក្សាអំពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម។ ម្យ៉ាងទៀត ទិដ្ឋភាពសំខាន់ៗនៃកំណែទម្រង់ច្បាប់ និងតុលាការអាចត្រូវបានពិភាក្សានៅក្នុងវគ្គទីពីរនៃកិច្ចប្រជុំ ស្តីពីផលិតភាពកសិកម្ម ដែលគប្បីរួមបញ្ចូលនូវការផ្តល់អំណាចជូនដល់កសិករខ្នាតតូច ការផ្តល់ការកាន់កាប់ដីប្រកបដោយសុវត្ថិភាព ជាមួយនឹងគោលដៅរួមនៃការធ្វើឱ្យប្រសើរឡើងថែមទៀតនូវសន្តិសុខស្បៀង។

*សម្តេច ឯកឧត្តម លោកជំទាវ លោក និងលោកស្រី ជាទីគោរព:*

ខណៈដែលការពង្រឹងនូវការអនុវត្តក្របខ័ណ្ឌគតិយុត្តិមានស្រាប់គឺជាបញ្ហាសំខាន់បំផុត អង្គការមិនមែនរដ្ឋាភិបាលសូមស្វាគមន៍សកម្មភាពជាក់ស្តែងផ្សេងទៀតរបស់រាជរដ្ឋាភិបាល ដោយមានការជួយគាំទ្រពីដៃគូអភិវឌ្ឍន៍ ដែលជំរុញបន្ថែមទៀតនូវការប្រកាន់គោលការណ៍ប្រជាធិបតេយ្យ ការពិភាក្សាបើកទូលាយ និងក្នុងលក្ខណៈស្ថាបនា និង ការពង្រឹងអនុលោមភាពចំពោះអភិបាលកិច្ចល្អ។ ក្នុងន័យនេះ អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការនៅក្នុងវិស័យសុខភាព អប់រំ ធនធានធម្មជាតិ និងអភិបាលកិច្ច សូមវាយតម្លៃខ្ពស់យ៉ាងស្មោះចំពោះការងារកំពុងអនុវត្តលើសិទ្ធិស្តីពីការទទួលបានព័ត៌មាន ហើយយើងខ្ញុំជឿជាក់ថាសិទ្ធិស្តីពីការទទួលបានព័ត៌មាននឹងត្រូវបានអនុម័តទៅជាច្បាប់មួយនៅក្នុងពេលអនាគតដ៏ខ្លី។

សិទ្ធិស្តីពីការទទួលបានព័ត៌មានគឺជាគ្រឿងផ្សំដ៏សំខាន់មួយនៅក្នុងការសម្រេចបានគោលដៅគន្លឹះដ៏ឧត្តមនៃអភិបាលកិច្ចល្អរបស់រាជរដ្ឋាភិបាល។ ច្បាប់ដែលធានានូវការទទួលបានព័ត៌មាននេះអនុញ្ញាតឱ្យប្រជាជនទទួលបានទិន្នន័យនិងព័ត៌មានសំខាន់ៗដែលគ្រប់គ្រងដោយរាជការ និងចូលរួមចំណែកធ្វើឱ្យប្រសើរឡើងនូវតម្លាភាព និងគណនេយ្យភាពទូទៅរបស់ភាគីពាក់ព័ន្ធទាំងអស់។ អង្គការមិនមែនរដ្ឋាភិបាល សូមអបអរសាទររាជរដ្ឋាភិបាលចំពោះការផ្សព្វផ្សាយជាសាធារណៈបន្ថែមទៀតនូវ ព័ត៌មានមួយចំនួនទាក់ទិននឹងថវិកាជាតិនៅក្នុងអំឡុងពេល ១៨ ខែចុងក្រោយនេះ ជាក់ស្តែង របាយការណ៍សវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៦ និង ទិន្នន័យប្រាក់ចំណូលសរុបប្រចាំខែដែលទទួលបានពីក្រុមហ៊ុនទាំងឡាយនៅក្នុងវិស័យឧស្សាហកម្មនិស្សារណៈកម្ម(ប្រេងកាត ឧស្ម័ន និង រ៉ែ)។ ដើម្បីជម្រុញតម្លាភាព និងគណនេយ្យភាពបែបនេះបន្ថែមទៀតនៅក្នុងគ្រប់វិស័យទាំងអស់ កម្ពុជាមុខជាទទួលបានអត្ថប្រយោជន៍ពីច្បាប់ស្តីពីការទទួលបានព័ត៌មាន។ ច្បាប់នេះនឹងអាចជួយជំរុញឱ្យមានទំនុកចិត្ត និងការជឿជាក់រវាងរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា និងមុខជាផ្តល់អំណាចឱ្យប្រជាជនកាន់តែច្រើនឡើងក្នុងការចូលរួមក្នុងកិច្ចដំណើរការនយោបាយ និងការអភិវឌ្ឍន៍ ដែលរួមចំណែកដល់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពរបស់យើង។ ទន្ទឹមនឹងនេះ អង្គការមិនមែនរដ្ឋាភិបាលសូមស្នើរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍បន្តផ្តល់អាទិភាពដល់ការទទួលបានព័ត៌មានរបស់សាធារណជននៅក្នុងគ្រប់កម្មវិធីកំណែទម្រង់តាមវិស័យទាំងអស់។

*សម្តេច ឯកឧត្តម លោកជំទាវ លោក និងលោកស្រី ជាទីគោរព:*

យើងខ្ញុំបាទសូមបញ្ចប់នូវសេចក្តីថ្លែងការណ៍ទាំងនេះ ដោយសូមទាញការយកចិត្តទុកដាក់របស់សម្តេច ឯកឧត្តម លោកជំទាវ លោក និងលោកស្រី សូមផ្តោតលើសូចនាករតាមដានរួម។ អង្គការមិនមែនរដ្ឋាភិបាលសូមអបអរសាទរក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ចំពោះទម្រង់ថ្មី និងកាន់តែល្អនៃសូចនាករតាមដានរួមដែលគឺជាការបង្ហាញនូវការយល់គ្នាស៊ីជម្រៅ និងភាពជាដៃគូកាន់តែរឹងមាំរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍។ យើងខ្ញុំសូមអបអរសាទរការប្រឹងប្រែងរួមពីភាគីទាំងពីរ ដែលជាហេតុ

ធ្វើឱ្យកាន់តែប្រសើរឡើងដល់គណនេយ្យភាពទ្វេទិស និង ការឈានទៅសម្រេចបាននូវលទ្ធផល។ តាមទស្សនៈរបស់អង្គការមិនមែនរដ្ឋាភិបាល ទម្រង់ថ្មីនេះធ្វើឱ្យការប្តេជ្ញាដែលបានធ្វើនៅក្នុងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទីមួយ និងទីពីរមានលក្ខណៈហួសសម័យ។ ដើម្បីធានាឱ្យបាននូវភាពអាចទុកចិត្តបាននៃវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា អង្គការមិនមែនរដ្ឋាភិបាលសូមសម្តែងទស្សនៈរបស់ខ្លួនថាសូចនាករតាមដានរួមសំខាន់ៗដែលមិនទាន់សម្រេចបាន គួរត្រូវដាក់បញ្ចូលជាស្វ័យប្រវត្តិទៅក្នុងទម្រង់សូចនាករថ្មីនេះ។ ក្នុងន័យនេះ យើងខ្ញុំសូមទាញការយកចិត្តទុកដាក់របស់សម្តេច ឯកឧត្តម លោកជំទាវ លោក និងលោកស្រី សូមផ្តោតលើសូចនាករតាមដានរួមមុនសម្រាប់វិស័យដីធ្លី និងព្រៃឈើ ដែលហាក់បីដូចជាមិនមានដាក់បញ្ចូលក្នុងសូចនាករតាមដានរួមថ្មីដែលបានស្នើឡើង។ យើងខ្ញុំសង្ឃឹមយ៉ាងស្មោះថា វេទិកានេះនឹងគិតគូរដល់ចំណុចនេះនៅក្នុងពេលពិភាក្សានៅក្នុងវគ្គទីបួននៃកិច្ចប្រជុំស្តីពីការអនុម័តសូចនាករតាមដានរួម មុនបទបង្ហាញអំពីក្របខ័ណ្ឌហិរញ្ញប្បទានណែនាំពហុឆ្នាំ។

យើងខ្ញុំសូមថ្លែងអំណរគុណ និងសង្ឃឹមថាចំណុចដែលត្រូវបានលើកឡើងខាងលើទាំងនេះនឹងត្រូវបានពិចារណា និងផ្តល់តម្លៃខ្ពស់ដោយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍។